# សេចក្ដីណែនាំដល់ថ្នាក់ដឹកនាំស្ដីពីព្រះវិហារបរិសុទ្ធ និងពង្សប្រវត្តិ ឆ្នាំ ២០២៤

## គោលការណ៍ណែនាំសម្រាប់ការពិភាក្សា

សូមអរគុណដែលបានជួបជុំគ្នា និងមើលសេចក្ដីណែនាំដល់ថ្នាក់ដឹកនាំស្ដីពីព្រះវិហារបរិសុទ្ធ និងពង្សប្រវត្តិ ក្នុងនាមជាថ្នាក់ដឹកនាំ ។ កាលអ្នកមើលសារលិខិតនេះ យើងសូមអញ្ជើញអ្នកឲ្យប្រឹក្សារួមគ្នា ។ សូមពិចារណាប្រើប្រាស់សំណួរខាងក្រោមនេះទុកជាគោលការណ៍ណែនាំ ឬកែសម្រួលវាទៅតាមតម្រូវការរបស់ក្រុមប្រឹក្សាអ្នក ។ សូមពិចារណារំឭកឡើងវិញក្នុង « គោលការណ៍នៃក្រុមប្រឹក្សាដែលមានប្រសិទ្ធភាព » ( *ក្បួនខ្នាតទូទៅ ៖ ការបម្រើនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ* ៤.៤ ) ។

១. តើព្រះវិញ្ញាណបានបង្រៀនអ្នកអ្វីខ្លះ នៅពេលអ្នកស្ដាប់ឮសេចក្ដីណែនាំនេះ ?

២. តើនរណាខ្លះដែលយើងអាចជួយឲ្យមានបទពិសោធន៍ដ៏ល្អជាមួយពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ជាលើកដំបូង ? សូមពិចារណាសរសេរឈ្មោះពួកគេ ។

៣. តើយើងអាចជួយអ្នកដឹកនាំម្នាក់ៗក្នុងសាសនាចក្រឲ្យប្រើប្រាស់ ពិធីបរិសុទ្ធត្រៀមរួច និង ជំនួយឈ្មោះព្រះវិហារបរិសុទ្ធ ដោយរបៀបណា ?

សូមពិចារណាថា តើធនធានខាងក្រោមនេះណាមួយដែលអាចមានប្រយោជន៍ នៅពេលអ្នកជួយសម្របសម្រួលឲ្យមានបទពិសោធន៍វិជ្ជមាននៅព្រះវិហារបរិសុទ្ធជាលើកដំបូង ៖

- បង្កើតគណនីកម្មវិធីស្រាវជ្រាវក្រុមគ្រួសារ ។
- ជួបជាមួយអ្នកប្រឹក្សាយោបល់ខាងព្រះវិហារបរិសុទ្ធ និងពង្សប្រវត្តិដើម្បីទទួលបានជំនួយ ។
- បន្ថែមរូបតំណាងអ្នកជួយមកពីគេហទំព័រ ។
- ពិនិត្យមើលធនធានអ្នកជួយនៅលើគេហទំព័រ FamilySearch.org ។ ?
- ស្វែងយល់ពីជំនួយឈ្មោះព្រះវិហារបរិសុទ្ធ នៅលើធនធានសម្រាប់ថ្នាក់ដឹកនាំ និងស្មៀន ។

*« ខ្ញុំសូមសន្យានឹងបងប្អូនថា រាល់កិច្ចខិតខំទាំងអស់ រាល់ការខំប្រឹងតិចតួចទាំងឡាយដើម្បីព្យាយាមជួយអ្នកប្រែចិត្តជឿថ្មី … ឲ្យរកឃើញផ្លូវរបស់ពួកគេទៅកាន់ព្រះដំណាក់នៃព្រះអម្ចាស់ នឹងមិនគ្រាន់តែផ្ដល់ពរជ័យដល់បុគ្គលនោះប៉ុណ្ណោះទេ ប៉ុន្តែខ្ញុំក៏សូមសន្យាថា វានឹងផ្ដល់ពរជ័យដល់បងប្អូនផងដែរ ។ វានឹងផ្ដល់ពរដល់សមាជិកក្នុងវួដរបស់បងប្អូន ។ សេចក្ដីជំនឿរបស់បងប្អូនលើព្រះយេស៊ូវគ្រីស្ទនឹងកើនឡើង ហើយការយល់ដឹង និងសេចក្ដីស្រឡាញ់របស់បងប្អូនចំពោះដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញនឹងរីកចម្រើនឡើង នៅពេលបងប្អូនទទួលបទពិសោធន៍ពីពរជ័យព្រះវិហារបរិសុទ្ធជាមួយសមាជិកថ្មីនៃសាសនាចក្ររបស់យើង » ។*

អែលឌើរ នែល អិល អាន់ឌើរសិន

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© 2024 by Intellectual Reserve, Inc. All rights reserved. កំណែ ៖ 10/23 ។ ការបកប្រែនៃ *Temple and Family History Leadership Instruction 2024* ។ Cambodian ។ PD80025686 258 ។ បានបោះពុម្ពនៅសហរដ្ឋអាមេរិក